**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ :..០៤០..សព្រក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី ស្ថានភាពពលរដ្ឋភៀសសឹក ផលប៉ះពាល់លើតំបន់ស៊ីវិល
# គិតពីម៉ោង៦ព្រឹក ថ្ងៃទី៣ ដល់ម៉ោង៦ព្រឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦
# និងគោលជំហរក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិជ្រាបថា ចាប់តាំងពីបទឈប់បាញ់រវាងកម្ពុជា និងថៃ ចូលជាធរមាន កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥មក ភាគីទាំងសងខាងពុំបានផ្ទុះអាវុធដាក់គ្នានោះឡើយ។ យ៉ាងណាក៏ដោយក្នុងរយៈពេលនេះ កម្ពុជាបានតាមដាន និងកត់ត្រាទុកជាបន្តបន្ទាប់ នូវសកម្មភាពមិនស្មោះត្រង់មួយចំនួនរបស់ភាគីថៃ។ ចំណែកផលប៉ះពាល់លើប្រជាពលរដ្ឋ និងតំបន់ស៊ីវិលកម្ពុជា ដែលបង្កឡើងដោយអំពើឈ្លានពាននោះ ក៏នៅតែជាបន្ទុកត្រូវដោះស្រាយជាអាទិភាពរបស់រាជរដ្ឋាភិបាល។ **ក្រសួងមហាផ្ទៃ** សូមផ្តល់ជូនបច្ចុប្បន្នភាពនៃសភាពការណ៍ជារួម គិតពីម៉ោង៦ព្រឹក ថ្ងៃទី៣ ដល់ម៉ោង៦ព្រឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦នេះ ជាមួយនឹងការគូសបញ្ជាក់ជាថ្មីទៀតនូវគោលជំហរសំខាន់ៗ ដូចខាងក្រោម៖

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** មានពលរដ្ឋភៀសសឹក៦.២២១នាក់បន្ថែមទៀត បានបន្តវិលត្រឡប់ទៅលំនៅឋានវិញ។ ក្នុងចំណោមពលរដ្ឋភៀសសឹកសរុបជាង៦សែន៤ម៉ឺននាក់ មានជាង៥សែន៥ម៉ឺននាក់ ឬជិត៨៥% បានវិលត្រឡប់ទៅលំនៅឋានវិញហើយ។ មានពលរដ្ឋភៀសសឹកចំនួន៩៧.៨៧៨នាក់ទៀត កំពុងបន្តស្នាក់អាស្រ័យតាមជំរំនានា ក្នុងនោះស្ត្រីមានចំនួន៥១.២៤៨នាក់ និងកុមារចំនួន៣១.២៩៧នាក់។

**២-ការបន្តបិទផ្អាកសេវាសាធារណៈជាមូលដ្ឋាន៖ ខេត្តឧត្តរមានជ័យ** មានសាលារៀន១៤ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព៧ បន្តបិទផ្អាក។ **ខេត្តបន្ទាយមានជ័យ** មានសាលារៀន៥ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១ បន្តបិទផ្អាក។ **ខេត្តព្រះវិហារ** មានសាលារៀន២៩ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ នៅបន្តបិទផ្អាក។ ក្នុងនាមជាសេនាធិការរាជរដ្ឋាភិបាល លើការងារគ្រប់គ្រងរដ្ឋបាលដែនដី **ក្រសួងមហាផ្ទៃ** បានកំពុងដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិសហការជាមួយក្រសួង-ស្ថាប័ននានា ដើម្បីជំរុញការស្តារជីវភាពប្រជាពលរដ្ឋ និងសេវាសាធារណៈដែលបានប៉ះពាល់ និងបិទផ្អាក ឱ្យវិលមករកភាពប្រក្រតីឡើងវិញជាបន្តបន្ទាប់ទៀត ជាពិសេសកិច្ចគាំពារ និងការគាំទ្រគ្រប់បែបយ៉ាងដល់ប្រជាពលរដ្ឋភៀសសឹកដែលពុំទាន់អាចវិលចូលទៅរស់នៅក្នុងផ្ទះសំបែងវិញបាន។

**៣-ការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** គិតចាប់ពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥មក **ការខូចខាតទ្រព្យសម្បត្តិឯកជន** សរុប រួមមាន ផ្ទះ៩៨០ខ្នង អគារស៊ីវិលឯកជន៧ អគារស្នាក់នៅ/សណ្ឋាគារ១០ ស្ថានីយប្រេង៤ ផ្សារឯកជន១ រថយន្ត៣៤គ្រឿង ម៉ូតូ១០គ្រឿង លានទិញដំឡូង១ អគារឃ្លាំងទំនិញ១ បង្គោលអង់តែនទូរសព្ទ៣ អាងទឹកនិងប្រព័ន្ធទឹកស្អាត៦កន្លែង ជង្រុកស្រូវ១ និងសត្វពាហនៈ/សត្វព្រៃ២ក្បាល។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** សរុប រួមមាន សាលារៀន២៦ មន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ សំណង់អគារ៤២ វត្តអារាម១៩ សាលាឆទាន១ រូបសំណាក២ រថយន្ត១គ្រឿង ប្រាសាទបុរាណ៤ ស្ពាន៥ ផ្សារ១ ផ្លូវ៨៧ ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី១ទីតាំង និងបណ្តាញបញ្ជូនអគ្គិសនី៣កន្លែង ខណៈអាជ្ញាធរមូលដ្ឋានបន្តស្រង់ទិន្នន័យផលប៉ះពាល់បន្ថែម។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** គោរពនិងគាំទ្រពេញទំហឹង ការបញ្ជាក់ច្បាស់ៗរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ថា កម្ពុជានឹងមិនធ្វើសម្បទាននូវអធិបតេយ្យ ឬសេចក្តីថ្លៃថ្នូររបស់ខ្លួនឡើយ។លមប:៧

ដូចគ្នានេះដែរ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានមានប្រសាសន៍យ៉ាងច្បាស់ៗហើយថា **រាជរដ្ឋាភិបាលកម្ពុជា នៅតែប្រកាន់ជំហរយ៉ាងរឹងមាំបំផុត ដើម្បីទាមទារមកវិញនូវបូរណភាពទឹកដី ស្របតាមច្បាប់ ដោយមិនបោះបង់ចោលតំបន់ណាមួយឡើយ។ រាល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបទឈប់បាញ់នាពេលកន្លងមក មិនមែនជាថ្នូរនៃការដោះដូរទឹកដី ឬដើម្បីកាត់ដីឱ្យទៅប្រទេសថៃនោះទេ ពោលគឺការដោះស្រាយបញ្ហាព្រំដែន ត្រូវតែផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិយ៉ាងម៉ឺងម៉ាត់ ទាំងការងារបច្ចេកទេសវាស់វែង និងការគ្រប់គ្រង។**

ក្នុងន័យនេះ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមគាំទ្រការតវ៉ាយ៉ាងដាច់អហង្ការរបស់រាជរដ្ឋាភិបាលចំពោះសកម្មភាពរបស់យោធាថៃ ចុះត្រួតពិនិត្យទីតាំងសណ្ឋាគារចំនួនពីរស្ថិតក្នុងស្រុកអូរស្មាច់ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦ ដោយគ្មានការអនុញ្ញាតពីភាគីកម្ពុជា ជារដ្ឋម្ចាស់ផ្ទះ។ សកម្មភាពនេះ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើដែនអធិបតេយ្យ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដែលមានចម្ងាយរហូតដល់ទៅ ៣៩៧ម៉ែត្រឯណោះ ពីច្រកទ្វារអន្តរជាតិអូរស្មាច់ ក្បែរបង្គោលព្រំដែនលេខ១៥ និងដែលទើបកងកម្លាំងប្រដាប់អាវុធថៃឈ្លានពានចូលកាន់កាប់ដោយខុសច្បាប់ ក្រោយបទឈប់បាញ់ចូលជាធរមាន។ សកម្មភាពទាំងនេះ មិនត្រឹមតែរំលោភលើធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការប៉ុនប៉ងបង្កើតភាពស្របច្បាប់នៃ «**ការកាន់កាប់ដោយខុសច្បាប់**» របស់ថៃ លើដែនអធិបតេយ្យរបស់កម្ពុជាថែមទៀតផង។

ជាថ្មីម្តងទៀត **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមអំពាវនាវមិត្តអាស៊ាន មិត្តបរទេស និងអង្គការសហប្រជាជាតិ បន្តចូលរួមគាំទ្រការដោះស្រាយជម្លោះព្រំដែនកម្ពុជា-ថៃ តាមគោលការណ៍សន្តិវិធី ស្របតាមច្បាប់អន្តរជាតិ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលភាគីទាំងពីរមានជាមួយគ្នាស្រាប់ ដោយប្រកាន់ខ្ជាប់ឥតងាករេនូវជំហរជាគោលការណ៍យ៉ាងម៉ឺងម៉ាត់ថា **ព្រំដែនមិនត្រូវបានផ្លាស់ប្តូរដោយការប្រើប្រាស់កម្លាំងឡើយ** ដើម្បីសន្តិភាព និងស្ថិរភាពនៃប្រទេស និងប្រជាជនទាំងសងខាង ក៏ដូចជាសម្រាប់តំបន់ និងសកលលោក។ យើងក៏សូមអំពាវនាវជនរួមជាតិ បន្តស្មារតីរួបរួមសាមគ្គីជាធ្លុងមួយ ដោយឈរលើព្រលឹងជាតិខ្មែរតែមួយតរៀងទៅ ចៀសវាងចាញ់ឧបាយកលនយោបាយក្រុមប្រឆាំងជ្រុលនិយម ដែលបានកំពុងបង្កើតព័ត៌មានក្លែងក្លាយ បំបែកបំបាក់សាមគ្គីជាតិ ធ្វើឱ្យប៉ះពាល់ឧត្តមប្រយោជន៍ជាតិ ជាពិសេសកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយជម្លោះព្រំដែន តាមគោលការណ៍សន្តិវិធី ឈរលើច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងនានាជាធរមាន។

ថ្ងៃពុធ ២រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦